# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 08-Feb-2016, 16:00
CMS/CFO: Sann Rada

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ: សហព្រះរាជអាជ្ញា

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៦

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះតុលាការកំពូល: **សាធារណៈ/Public**

ឋានៈនៃចំណាត់ថ្នាក់ឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## ឯកសារសម្អាងផ្លូវច្បាប់បន្ថែមរបស់សហព្រះរាជអាជ្ញាសម្រាប់សវនាការលើបណ្ដឹងសាទុក្ខ

---

<u>ដាក់ដោយ៖</u>

**សហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

<u>ផ្ញើជូន៖</u>

**ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រីម ប្រធាន

ចៅក្រម A. KLONOWIECKA-MILART

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម C.N. JAYASINGHE

ចៅក្រម ម៉ុង មុនីចរិយា

ចៅក្រម យ៉ា ណារិន

ចៅក្រម Florence Ndepele Mwachande MUMBA

<u>ចម្លងជូន៖</u>

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Marie GUIRAUD

**ជនជាប់ចោទ៖**

នួន ជា

ខៀវ សំផន

**មេធាវីការពារក្ដី៖**

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ

# I. សំណើ

1. ការិយាល័យសហព្រះរាជអាជ្ញា (“សហព្រះរាជអាជ្ញា”) ដាក់សំណើនេះ ដើម្បីពឹងផ្អែកលើឯកសារសម្អាងផ្លូវច្បាប់បន្ថែមទៀត ទាក់ទងនឹងការលើកសំណួរចំនួនប្រាំដែលបានដាក់ដោយអង្គជំនុំជម្រះតុលាការកំពូល នៅសវនាការលើបណ្តឹងសាទុក្ខដែលបានកំណត់កាលបរិច្ឆេទឡើងវិញ និងភ្ជាប់ជាមួយនូវឯកសារសម្អាងផ្លូវច្បាប់ទាំងនោះជាឧបសម្ព័ន្ធនានាខាងក្រោម។

2. នៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៥ អង្គជំនុំជម្រះតុលាការកំពូល (“តុលាការកំពូល”) បានដាក់សំណួរចំនួនប្រាំសម្រាប់ភាគីនានាដើម្បីដោះស្រាយនៅពេលសវនាការលើបណ្តឹងសាទុក្ខ។ អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់បន្ថែមទៀតឲ្យភាគីនានាដាក់ មិនឲ្យហួសថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥ នូវឯកសារសម្អាងផ្លូវច្បាប់នានាដែលខ្លួនមានបំណងពឹងផ្អែកលើ ក្នុងអំឡុងពេលសវនាការលើបណ្តឹងសាទុក្ខដែលក្រោយមកបានកំណត់កាលបរិច្ឆេទចាប់ផ្តើមបួនថ្ងៃ ក្រោយមកទៀត នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥[1]។

3. ដោយសារតែពេលវេលាបន្ថែមចាប់តាំងពីការពន្យារពេលសវនាការ លើបណ្តឹងសាទុក្ខនោះមក សហព្រះរាជអាជ្ញាបានធ្វើការស្រាវជ្រាវបន្ថែមទៀត នូវបញ្ហាស្មុគស្មាញនានាដែលបានលើកឡើងដោយអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងសំណួរទាំងប្រាំនោះ ហើយបានរកឃើញឯកសារសម្អាងផ្លូវច្បាប់មួយចំនួនបន្ថែមទៀត ដែលសហព្រះរាជអាជ្ញាជឿជាក់ថាមានភាពពាក់ព័ន្ធ និងដែលអាចជួយអង្គជំនុំជម្រះក្នុងការពិចារណារបស់ខ្លួនលើបញ្ហាទាំងនេះ។ សហព្រះរាជអាជ្ញាយល់ឃើញថា វាស្ថិតនៅក្នុងផលប្រយោជន៍យុត្តិធម៌ដែលភាគីទាំងឡាយ និងអង្គជំនុំជម្រះគួរទទួលបានសម្ភារៈទាំងអស់នេះ មុនពេលសវនាការ ហើយហេតុដូច្នេះស្នើសុំការអនុញ្ញាតធ្វើការកែតម្រូវបញ្ជីដែលបានដាក់ពីមុន ដើម្បីបញ្ចូលឯកសារសម្អាងផ្លូវច្បាប់ទាំងអស់នេះ។

---

[1] **F30/4** ដីកាកំណត់កាលវិភាគស្តាពរសម្រាប់សវនាការបណ្តឹងសាទុក្ខ និងការជូនដំណឹងភាគីអំពីបញ្ហាដែលត្រូវលើកឡើង, ៥ វិច្ឆិកា ២០១៥ (“ដីកាកំណត់សវនាការបឋមលើបណ្តឹងសាទុក្ខ”)។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៦ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញាជាតិ | ភ្នំពេញ | |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | | |